# កម្មវិធីសាលារៀនជំនាន់ថ្មី

## ត្រូវការជ្រើសរើស

## គិលានុបដ្ឋាក គិលានុបដ្ឋាយិកាដែលមានសមត្ថភាពខ្ពស់

អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា គឺជាអង្គការក្នុងស្រុកមួយដែលសហការជាដៃគូជិតស្និទ្ធជាមួយក្រសួងអប់រំ យុវជន និងកីឡា មូលនិធិគ្រួសារត្រកូលប្រែហ្វង់ស៍ (FFF) និងអង្គការឆាលហ្វានកម្ពុជា ដើម្បីអនុវត្តកម្មវិធីសាលារៀនជំនាន់ថ្មី នៅវិទ្យាល័យព្រែកលៀប និងវិទ្យាល័យព្រះស៊ីសុវត្ថិ រាជធានីភ្នំពេញ វិទ្យាល័យ **ហ៊ុន សែន** កំពង់ចាម វិទ្យាល័យ **ហ៊ុន សែន** ពាមជីកង ខេត្តកំពង់ចាម វិទ្យាល័យគោកព្រីង ខេត្តស្វាយរៀង និងវិទ្យាល័យ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ព្រែកអញ្ចាញ ខេត្តកណ្តាល។ កម្មវិធីសាលារៀនជំនាន់ថ្មី គឺជាផ្នែក មួយនៃកម្មវិធីកំណែទម្រង់ថ្មីរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលនឹងកែលម្អគុណភាពអប់រំ និងអភិបាល កិច្ចល្អ នៅក្នុងវិស័យអប់រំ។ ដូចនេះកម្មវិធីសាលារៀនជំនាន់ថ្មីត្រូវការស្វែងរកគិលានុបដ្ឋាក គិលានុបដ្ឋាយិកា ដែលមានសមត្ថភាពខ្ពស់ក្នុងការផ្តល់ប្រឹក្សា ឬសង្គ្រោះបឋមដល់សិស្សានុសិស្សក្នុងសាលាគោលដៅ ដូចខាងក្រោម៖

| មុខវិជ្ជាជ្រើសរើស | វិទ្យាល័យ ព្រែកលៀប | វិទ្យាល័យ ព្រែកអញ្ចាញ | វិទ្យាល័យ ហ៊ុន សែន ពាមជីកង | វិទ្យាល័យ ហ៊ុន សែន កំពង់ចាម | វិទ្យាល័យ ព្រះស៊ីសុវត្ថិ | វិទ្យាល័យ គោកព្រីង |
|---|---|---|---|---|---|---|
| | ចំនួនជ្រើសរើស | ចំនួនជ្រើសរើស | ចំនួនជ្រើសរើស | ចំនួនជ្រើសរើស | ចំនួនជ្រើសរើស | ចំនួនជ្រើសរើស |
| គិលានុបដ្ឋាក/គិលានុបដ្ឋាយិកា | | ១នាក់ | ១នាក់ | | | ១នាក់ |
| **សរុបរួម** | | **១នាក់** | **១នាក់** | | | **១នាក់** |

### ១. តួនាទី និងភារកិច្ចរបស់គិលានុបដ្ឋាក គិលានុបដ្ឋាយិកា៖

- គ្រប់គ្រងគិលានដ្ឋានមួយនៅក្នុងសាលា ដែលរួមមានបន្ទប់ពិនិត្យជំងឺ និងបន្ទប់សម្រាកព្យាបាលសម្រាប់សិស្សមានជំងឺ។
- ផ្តល់សេវាសុខភាពមូលដ្ឋានដល់សិស្សទាំងអស់ក្នុងវិទ្យាល័យ ដូចជា ការសង្គ្រោះបឋម ផ្តល់អាហារូបត្ថម្ភនិងការព្យាបាលបឋមដូចជា ឈឺក្បាល ចុកពោះ ឬអស់កម្លាំងជាដើម។ល។
- ផ្តល់សេវាបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យបង្អែក (មន្ទីរពេទ្យក្នុងមូលដ្ឋាន) ចំពោះសិស្សដែលមានជំងឺធ្ងន់ធ្ងរ ដែលទាមទារការព្យាបាលពីវេជ្ជបណ្ឌិត។
- ផ្តល់សេវាគាំទ្រការពិគ្រោះជំងឺដល់សិស្សដែលឈានចូលដល់វ័យរៀបការ ជាពិសេសសិស្សស្រី។
- រៀបចំកំណត់ត្រាពិនិត្យសុខភាព និងចងក្រងទុកសម្រាប់សិស្សដែលទទួលសេវាសុខភាពនៅក្នុងគ្លីនិកសាលា។
- ថែទាំងរាល់បរិក្ខាពេទ្យដែលគម្រោងបានផ្តល់ជូនគិលានដ្ឋានរបស់សាលា។

- ❖ គ្រប់គ្រងថែទាំងឱ្យបានហ្មត់ចត់ការទទួល និងបែងចែកបរិក្ខារវេជ្ជសាស្ត្រ ថ្នាំពេទ្យ និងអាហារបន្ថែម ដែលកម្មវិធីផ្តល់ឱ្យ។
- ❖ ធ្វើរបាយការណ៍ជាលាយលក្ខអក្សរសម្រាប់រាយការណ៍ជូនកម្មវិធី (ប្រចាំខែ ឬត្រីមាស)។
- ❖ សហការយ៉ាងជិតស្និទ្ធជាមួយនាយកសាលា ក្នុងការគ្រប់គ្រងសេវាសុខភាពនៅក្នុងសាលា។
- ❖ សហការយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាកុមារដើម្បីផ្សព្វផ្សាយពីសារសុខភាព ដល់គណៈកម្មការសិក្សានិងសិស្សនៅក្នុងសាលា។

អង្គការខេបកំពុងត្រូវការគិលានុបដ្ឋាក គិលានុបដ្ឋាយិកាដែលមានសមត្ថភាពពេញលេញ និងមានបទពិសោធន៍យ៉ាងតិច២ឆ្នាំ។ បេក្ខជនសក្តិសមជាអ្នកធ្វើការងារក្នុងក្រុម មានគំនិតច្នៃប្រឌិត មានបំណិនវិជ្ជាជីវៈពិតប្រាកដ រួសរាយរាក់ទាក់ ពូកែការងារទំនាក់ទំនង និងចូលចិត្តជួយគាំទ្រកុមារ និងយុវជន។

***កម្មវិធីត្រូវការគិលានុបដ្ឋាក គិលានុបដ្ឋាយិកា ដែលមានលក្ខណៈសម្បត្តិមួយចំនួន ឬទាំងអស់ដូចខាងក្រោម ៖***

១. មានសញ្ញាបត្រគិលានុបដ្ឋាក គិលានុបដ្ឋាយិកា

២. មានសញ្ញាបត្រ ឬលិខិតអនុញ្ញាតជាផ្លូវការក្នុងការបម្រើការងារជាគិលានុបដ្ឋាក គិលានុបដ្ឋាយិកា

៣. មានបទពិសោធន៍ផ្នែកគិលានុបដ្ឋាក គិលានុបដ្ឋាយិកាយ៉ាងតិច២ឆ្នាំ

៤. មានចំណេះដឹង និងបទពិសោធន៍ប្រើប្រាស់កុំព្យូទ័រច្បាស់លាស់

៥. មានសមត្ថភាពក្នុងការប្រាស្រ័យទាក់ទងជាភាសាខ្មែរ និងអង់គ្លេសច្បាស់លាស់ និងមានប្រសិទ្ធភាព

៦. មានបំណិនគ្រប់គ្រង និងចាត់ចែងច្បាស់លាស់

៧. មានឆន្ទៈបំពេញការងារជាមួយកម្មវិធីសាលារៀនជំនាន់ថ្មី

បេក្ខជនដែលចាប់អារម្មណ៍សូមផ្ញើប្រវត្តិរូបសង្ខេប និងលិខិតចំណាប់អារម្មណ៍មកលោក ប៊ាន ចាន់នី ប្រធានក្រុមសាលារៀនជំនាន់ថ្មី៖

- លេខទូរសព្ទសម្រាប់ទំនាក់ទំនង៖ ០១២ ២៩៤ ២២១ (email: channy.bean@kapekh.org )

- ❖ *កាលបរិច្ឆេទនៃការទទួលពាក្យ៖* *ថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣*
- ❖ *កាលបរិច្ឆេទនៃការឈប់ទទួលពាក្យ៖* *ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង៥ល្ងាច។*